C
P
D



# គណៈឆ្មបកម្ពុជា
# ក្រុមប្រឹក្សាគណៈឆ្មបជាតិ

## ព្រឹត្តិបត្រស្ដីអំពីការអភិវឌ្ឍវិជ្ជាជីវៈបន្ត

### អ្វីដែលអ្នកត្រូវដឹងក្នុងនាមជាអ្នកប្រកបវិជ្ជាជីវៈឆ្មប

ការអភិវឌ្ឍវិជ្ជាជីវៈ (CPD) ជួយអ្នកប្រកបវិជ្ជាជីវៈឆ្មបដែលមានអាជ្ញាបណ្ណឆ្មបដើម្បីរក្សា និងលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈរបស់ពួកគេ។ CPD ជួយអ្នកក្នុងការរក្សាបច្ចុប្បន្នភាពនៃការអនុវត្តវិជ្ជាជីវៈរបស់ខ្លួនដើម្បីធានាថាអ្នកផ្ដល់ជូនសេវាថែទាំមាតានិងទារកបែបទំនើបប្រកបដោយប្រសិទ្ធិភាព គុណភាព និងសុវត្ថិភាព ដល់អ្នកជំងឺ អតិថិជន ឬសហគមន៍អ្នក។អ្នកប្រកបវិជ្ជាជីវៈជាឆ្មបទាំងអស់ត្រូវបំពេញ៦០ពិន្ទុក្នុងមួយវដ្ត CPD ដែលមានរយៈពេល៣ឆ្នាំ។ ១ពិន្ទុ CPD=១ ម៉ោងនៃការសិក្សាសកម្មសូមមើលសកម្មភាពទាំងឡាយដែលត្រូវបានរាប់ជាសកម្មភាពCPD។គេហទំព័រគណៈឆ្មបកម្ពុជា
(http://www.cmidwivesc.org)
មានបញ្ជីនៃការបណ្ដុះបណ្ដាលដែលត្រូវបានទទួលស្គាល់ជាសកម្មភាព CPD។

**ជំហានទី ១**

ចុះបញ្ជិកា និងការទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈពីគណៈឆ្មបកម្ពុជា។

**ជំហានទី ២**

ធ្វើផែនការអភិវឌ្ឍរៀនសូត្រផ្ទាល់ខ្លួន។

**ជំហានទី ៣**

ចូលរួមវគ្គបណ្ដុះបណ្ដាលការអភិវឌ្ឍវិជ្ជាជីវៈបន្តដោយផ្ទាល់ ឬ ពីចំងាយ (online training) ។ល។ ជាមួយអង្គភាពផ្ដល់ការបណ្ដុះបណ្ដាលការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលមានការទទួលស្គាល់ដោយគណៈឆ្មបកម្ពុជានិងកត់ត្រាពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

**ជំហានទី ៤**

ដាក់ភស្តុតាងនៃសកម្មភាព(CPD) របស់អ្នកទៅគណៈឆ្មបកម្ពុជាសម្រាប់បន្តអាជ្ញាបណ្ណឡើងវិញ។

គោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តផ្តល់ព័ត៌មានបន្ថែមអំពីតម្រូវការ CPD របស់ គណៈឆ្មបកម្ពុជា (CMC)។ ស្វែងយល់បន្ថែមពី CMC អំពីរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជិកាតាមអនឡាញ (RMS) ក្នុងការកត់ត្រា និងតាមដានពិន្ទុ CPD របស់អ្នក។

## CPD ជាទំនួលខុសត្រូវរបស់អ្នក!

### តើត្រូវរាប់យ៉ាងដូចម្តេច?

| ល.រ | សកម្មភាព CPD | ចំនួនពិន្ទុ CPD | ចំនួនពិន្ទុ CPD អតិបរមាក្នុងមួយសកម្មភាព |
|---|---|---|---|
| ១ | ការពិភាក្សាករណីសិក្សាជាក្រុម/ចូលរួមការប្រជុំបច្ចេកទេស (ក្លឹប) | ១ពិន្ទុCPD សម្រាប់ម៉ោងរៀនសកម្មនីមួយៗ | ពិន្ទុ CPD ជាក់ស្តែង |
| ២ | ការសិក្សាដោយខ្លួនឯង* (អានអត្ថបទទិនានុប្បវត្តិនៅក្នុងទិនានុប្បវត្តិល្បីៗទាក់ទងនឹងសុខភាពឬការបោះពុម្ពផ្សាយតាម Internet ទាក់ទងនិងសុខភាព (Webinars) ឬ វីដេអូទាក់ទងនឹងសុខភាព)<br>• ត្រូវការភស្តុតាងជាលាយលក្ខណ៍អក្សរ | ១ពិន្ទុCPD សម្រាប់ម៉ោងរៀនសកម្មនីមួយៗ | រហូតដល់អតិបរមា ១០ ពិន្ទុ |
| ៣ | សិក្ខាសាលាបណ្តុះបណ្តាលឬសិក្ខាសាលាសម្រាប់រយៈពេលពី ១ - ≤ ២សប្តាហ៍ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ១៥ ពិន្ទុ |
| ៤ | ការបញ្ចប់ដោយជោគជ័យវគ្គសិក្សាខ្លីមានរយៈពេល >២ សប្តាហ៍ទៅ ៣ ខែ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ២៥ ពិន្ទុ |
| ៥ | ការបញ្ចប់ដោយជោគជ័យវគ្គសិក្សាដែលមានរយៈពេលខ្លី ពី ៣ ទៅ ៦ខែ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ៣៥ ពិន្ទុ |
| ៦ | ការបញ្ចប់ដោយជោគជ័យវគ្គសិក្សាដែលមានរយៈពេលខ្លី ពី >៦ ទៅ ១២ ខែ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ៤០ ពិន្ទុ |
| ៧ | បានចូលរួមការអប់រំនៅកន្លែងធ្វើការវគ្គសិក្សាក្នុងពេលបំពេញការងារ(In service training) ឬ កម្មវិធីអភិវឌ្ឍន៍ជំនាញ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | ពិន្ទុ CPD ជាក់ស្តែង |

| | | | |
|---|---|---|---|
| ៨ | ចូលរួមសន្និសីទក្នុងប្រទេសកម្ពុជា | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | ពិន្ទុ CPD ជាក់ស្តែង |
| ៩ | ចូលរួមសន្និសីទ សន្និបាត មហាសន្និបាតក្រៅប្រទេស | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ២០ ពិន្ទុ |
| ១០ | ស្រាវជ្រាវរៀបចំសម្រាប់ធ្វើបទបង្ហាញនៅម៉ោងបង្រៀនឬបទបង្ហាញក្នុងសន្និសីទជាតិឬអន្តរជាតិ (ដែលមិនមែនជាផ្នែកនៃការបង្រៀនដូចធម្មតា) | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | ពិន្ទុត្រូវបានកើនឡើងទ្វេដង រហូតដល់ អតិបរមា១០ពិន្ទុ CPD |
| ១១ | ការចូលរួមជាសមាជិកក្រុមស្រាវជ្រាវ ឬ ការងារគម្រោង | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ១០ ពិន្ទុ |
| ១២ | ការចូលរួមជាសមាជិកក្រុមក្នុងការធ្វើគោលនយោបាយពិធីសារនិងគោលការណ៍ណែនាំផ្សេងៗ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ១០ ពិន្ទុ |
| ១៣ | ស្រាវជ្រាវបន្ថែមនិងរៀបចំ ដើម្បីអភិវឌ្ឍតួនាទីជាគ្រូណែនាំតាមមន្ទីរពេទ្យ គ្រូណែនាំ គ្រូបង្វឹកបុគ្គលិកឬនិស្សិតហើយមានផែនការបណ្តុះបណ្តាលដែលមានឯកសារត្រឹមត្រូវ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ១០ ពិន្ទុ |
| ១៤ | ចូលរួមពិនិត្យនិងកែសម្រួលឯកសារអប់រំពាក់ព័ន្ធនឹងសុខាភិបាលអត្ថបទទិនានុប្បវត្តិ ជំពូកក្នុងសៀវភៅឬឯកសារសិក្សាស្រាវជ្រាវ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ១៥ ពិន្ទុ |
| ១៥ | ក្នុងនាមជាសហអ្នកនិពន្ធបោះពុម្ពផ្សាយអត្ថបទវិជ្ជាជីវៈឬអត្ថបទទាក់ទងសុខភាព ឬរបាយការណ៍សុខាភិបាលផ្សេងៗ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ១៥ ពិន្ទុ |
| ១៦ | សរសេរអត្ថបទសិក្សាស្រាវជ្រាវ ជាជំពូកសៀវភៅឬរបាយការណ៍ផ្សេងៗជាអ្នកនិពន្ធ ទី១និងបញ្ជូនដើម្បីចុះផ្សាយ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ២០ ពិន្ទុ |
| ១៧ | ចុះផ្សាយឯកសារ ជំពូកសៀវភៅឬរបាយការណ៍ពាក់ព័ន្ធ សុខាភិបាលក្នុងនាមអ្នកនិពន្ធទី១ | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ២០ ពិន្ទុ |
| ១៨ | ជាប្រធានដឹកនាំក្នុងការស្រាវជ្រាវពាក់ព័ន្ធសុខភាព | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ២៥ ពិន្ទុ |

| | | | |
|---|---|---|---|
| ១៩ | ជាប្រធានសម្របសម្រួលក្នុងការធ្វើគម្រោងទាក់ទងនឹងសុខភាព | ១ពិន្ទុCPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ២៥ ពិន្ទុ |
| ២០ | បញ្ចប់ថ្នាក់ក្រោយឧត្តមសិក្សា ដែលពាក់ព័ន្ធនឹងជំនាញនៅក្នុងនិងក្រៅប្រទេសដែលទទួលបានគុណវុឌ្ឍិជាផ្លូវការដូចជា សញ្ញាបត្របរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិតផ្នែកឆ្មប | ១ពិន្ទុ CPD ក្នុងមួយម៉ោងនៃការរៀនសូត្រសកម្ម | រហូតដល់អតិបរមា ៦០ ពិន្ទុ |